**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
**មន្ទីរបរិស្ថានខេត្តព្រះសីហនុ**
លេខ.................................បស្ថ.ខសន

# សេចក្តីប្រកាសព័ត៌មាន

មន្ទីរបរិស្ថានខេត្តព្រះសីហនុ សូមគោរពជម្រាបជូន **បណ្តាញសារព័ត៌មានជាតិ-អន្តរជាតិ និងសាធារណជន** អោយបានជ្រាបថា៖ ក្រោយពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រៃកទឹកសាបក្បាលឆាយមក ស្ថានភាពនៃសកម្មភាពបទល្មើស កាប់ឆ្ការព្រៃក្រៀវដើមឈើ ដាំដំណាំ សង់ខ្ទម និងបោះបង្គោលរបងហ៊ុំព័ទ្ធកាន់កាប់យកដីធ្វើជាកម្មសិទ្ធដោយខុសច្បាប់ក្នុងតំបន់ការពារត្រូវបានសមត្ថកិច្ចបរិស្ថានយើងចុះអនុវត្តវិធានការទប់ស្កាត់ជាបន្តបន្ទាប់។ក្នុងពេលថ្មីៗនេះសកម្មភាពនៃការចូលទន្ទ្រានកាន់កាប់ដីរដ្ឋនេះ មានការកំរើកឡើងគួរអោយកត់សម្គាល់។

មន្ទីរបរិស្ថានខេត្តព្រះសីហនុ សូមបញ្ជាក់ជូនផងដែរថា មានប្រជាពលរដ្ឋមួយក្រុម បានសាងសង់ទីជម្រកអនាធិបតេយ្យនៅលើដីដែលជាកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋមួយកន្លែង ហើយត្រូវបានម្ចាស់ដីឯកជននោះបណ្តេញចេញ។ ក្រោយពីត្រូវបានបណ្តេញចេញពីដីឯកជននោះមក ប្រជាពលរដ្ឋទាំងនោះ បានមកបោះទីតាំងនៅតំបន់អូរត្រាវ ភូមិ០១ សង្កាត់លេខ ០១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រៃកទឹកសាបក្បាលឆាយ។

នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០ កម្លាំងមន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្ត សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុងព្រះសីហនុ បានចុះអប់រំណែនាំ និងរុះរើ ទីជម្រកអនាធិបតេយ្យនៅទីតាំងចំណុចដូចបានរៀបរាប់ខាងលើម្តងរួចមកហើយ ប៉ុន្តែប្រជាពលរដ្ឋបានស្នើសុំធ្វើការរុះរើដោយខ្លួនឯង។ នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២០ កម្លាំងមន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្ត បានចុះទៅពិនិត្យមើលទីតាំងជាក់ស្តែងនោះម្តងទៀត បានឃើញថាមិនមានការរុះរើនោះឡើយ ប៉ុន្តែផ្ទុយទៅវិញពួកគាត់បាននាំគ្នាសង់ផ្ទះ និងខ្ទម បន្ថែមច្រើនជាងមុនទៅទៀត។

ដោយឈរលើគោលការណ៍សន្តិវិធី កាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២០ រដ្ឋបាលក្រុងព្រះសីហនុ បានអញ្ជើញតំណាងប្រជាពលរដ្ឋទាំងនោះចូលមកប្រជុំអប់រំណែនាំ ឲ្យរុះរើចេញពីទីតាំងនោះជាកំហិត ហើយពួកគាត់ក៏បានឯកភាពផងដែរថានឹងរុះរើចេញពីទីតាំងនោះអោយអស់ត្រឹមថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២០។

ជាក់ស្តែងនៅព្រឹកថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២០ កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តព្រះសីហនុ សហការជាមួយកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុងព្រះសីហនុ និងកម្លាំងមន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ បានចុះអនុវត្តវិធានការរដ្ឋបាលនៅទីតាំងនោះ បានជួបប្រជាពលរដ្ឋនៅទីតាំងជាក់ស្តែងប្រហែល ២០នាក់ ហើយពួកគាត់បានស្ម័គ្រចិត្តចាកចេញពីទីតាំងនោះដោយសន្តិវិធី និងមិនមានការតវ៉ាអ្វីនោះឡើយ។ ក្នុងប្រតិបត្តិការខាងលើនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តព្រះសីហនុ បានធ្វើការរុះរើខ្ទមអនាធិបតេយ្យចំនួន ៤៣ ខ្ទម ក្នុងនោះមានខ្ទមប្រក់តង់ចំនួន ៣៨ខ្ទម និងខ្ទមប្រក់ស័ង្កសីចំនួន ០៥ខ្ទម និងបំផ្លាញកូនស្វាយដាំថ្មីៗជាច្រើនដើម។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **បណ្តាញសារព័ត៌មានជាតិ-អន្តរជាតិ និងសាធារណជន** មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ...៧កើត...ខែ...អាសាឍ...ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ខេត្តព្រះសីហនុ ថ្ងៃទី...២៧...ខែ...កក្កដា...ឆ្នាំ ២០២០

ចម្លងជូន៖
- ក្រសួងបរិស្ថាន
- រដ្ឋបាលខេត្តព្រះសីហនុ
- ឯកឧត្តម សៀង សុខ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ
- រដ្ឋបាលក្រុងព្រះសីហនុ
- ឯកសារ-កាលប្បវត្តិ